ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៣ លេខ ១ ថ្ងៃទី ៨ ខែ មករា ឆ្នាំ ១៩៩៥

# រាជកិច្ច

រួមមានៈ

- ច្បាប់
- ក្រម- ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្ដីសំរេច
- សារាចរ

ផ្សាយចេញពីទីស្ដីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្ដាហ៍

# មាតិកា

# I- ធីស្តីការគណៈរដ្ឋមន្ត្រី

## ១.អនុក្រឹត្យ

០៥-១-១៩៩៥ - អនុក្រឹត្យលេខ ០១ អនក្រ ស្តីពីការលុបចោលអនុក្រឹត្យបង្កើតគណៈកម្មាធិការ អចិន្ត្រៃយ៍ចំរុះអន្តរក្រសួងទប់ស្កាត់បទល្មើសព្រៃឈើ បទល្មើសនេសាទ បទល្មើស កាប់ដើមកៅស៊ូ និង ដឹកជញ្ជូនជ័រកៅស៊ូ និង សេចក្តីសំរេចស្តីពីការបង្កើតគណៈកម្មការ ស្រាវជ្រាវត្រួតពិនិត្យ ធាតុភាពឈើមូល ឈើអារ................................ ១

០៥-១-១៩៩៥ -អនុក្រឹត្យលេខ ០២ អនក្រ ស្តីពីការធ្វើនិយ័តភាពថវិកាឆ្នាំ ១៩៩៤ ពីជំពូក ១០ ទៅជំពូក ១១ ២

០៥-១-១៩៩៥ -អនុក្រឹត្យលេខ ០៣ អនក្រ ស្តីពីប្រតិទិនឈប់សំរាកការងាររបស់មន្ត្រីរាជការ និយោជិក ៣ កម្មករប្រចាំឆ្នាំ ១៩៩៥ ................................ ៤

០៥-១-១៩៩៥ -អនុក្រឹត្យលេខ ០៤ អនក្រ ស្តីពីការបង្កើតគណៈកម្មការជាតិទទួលបន្ទុកការងារ ជំនួយ យោធាពី បរទេស ................................ ៥

០៤-១-១៩៩៥ -អនុក្រឹត្យលេខ ០១ អនក្រ ស្តីពីការជូនមេដាយស្ថាបនាជាតិ ................................ ៩

## ២.សេចក្តីសំរេច

០៥-១-១៩៩៥ -សេចក្តីសំរេចលេខ ០១ សសរ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង សំរាប់ការពារ និងសាងសង់ស្ថានីយ៍វារីអគ្គិសនី នៅគិរីរម្យ ................................ ១០

០៥-១-១៩៩៥ -សេចក្តីសំរេចលេខ ០២ សសរ ស្តីពីការបង្កើតអនុគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយ៍កម្ម និង សំណង់ខេត្តពោធិសាត់ ................................ ១២

០៥-១-១៩៩៥ -សេចក្តីសំរេចលេខ ០៣ សសរ ស្តីពីការបង្កើតអនុគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយ៍កម្ម និងសំណង់ ខេត្តកំពង់ចាម ................................ ១៤

០៥-១-១៩៩៥ -សេចក្តីសំរេចលេខ ០៤ សសរ ស្តីពីការបង្កើតអនុគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយ៍កម្ម និងសំណង់ ................................ ១៥

០៧-១-១៩៩៥ -សេចក្ដីសំរេចលេខ ០៥ សសរ ស្ដីពីនិតិវិធីក្នុងការនាំចេញឈើមូល ឈើអារ និងឈើកែច្នៃ
ទៅបរទេស ........................................................ ១៧

# II .ភាគខាងបណ្ដាក្រសួង

## ១.ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច .ហិរញ្ញវត្ថុ

### សារាចរ

០៦-១-១៩៩៥ -សារាចរលេខ ០០១ សរ ស្ដីពីការគ្រប់គ្រងមន្ត្រីរាជការតយនិងរដ្ឋាករ ........................ ២០

## ២.ទីស្ដីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

### ប្រកាស

០៣-១-១៩៩៥ -ប្រកាសលេខ ០០១ ពណបលប្រក ស្ដីពីការបង្កើតគណៈកម្មការរបស់ក្រសួងមួយដើម្បីសិក្សា
ស្រាវជ្រាវឯកជនភាវូបនីយកម្ម ........................................................ ២៤

## ៣. ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល

### ប្រកាស

០៦.១-៩៥ - ប្រកាសលេខ ១០ ផក.ប្រក អនុញ្ញាតអោយលោក ទុន សុខាន់ ជនជាតិខ្មែរ បើកដំណើរការ
រោងម៉ាស៊ីនកិនស្រូវកំលាំង ១៥ សេះ ........................................................ ២៥

០៦-១-៩៥ - ប្រកាសលេខ ១១ ផក.ប្រក អនុញ្ញាតអោយលោក លូ ធាង ជនជាតិខ្មែរ បើកដំណើរការ
ឡចំហុយថ្នាំសន្លឹកថ្នាំក្ងួតារ ........................................................ ២៥

០៦-១-៩៥ . ប្រកាសលេខ ១២ ផក.ប្រក អនុញ្ញាតអោយលោក អ៊ុច អេង ជនជាតិខ្មែរ បើកដំណើរការ
រោងម៉ាស៊ីនកិនស្រូវកំលាំង ១៨ សេះ ........................................................ ២៥

០៦-១-៩៥ - ប្រកាសលេខ ១៣ ផក.ប្រក អនុញ្ញាតអោយលោក គុយ អន ជនជាតិខ្មែរ បើកដំណើរការ
រោងជាងក្រឡឹងដែក ........................................................ ២៦

០៦-១-៩៥ - ប្រកាសលេខ ១៤ ផក.ប្រក អនុញ្ញាតអោយលោក ស៊ក ហ៊ិន ជនជាតិខ្មែរ បន្តដំណើរការ
រោងម៉ាស៊ីនកិនស្រូវកំលាំង ១៦ សេះ .................................................... ២

០៦-១-៩៥ - ប្រកាសលេខ ១៥ ផក.ប្រក អនុញ្ញាតអោយលោក ភិន ស្រ៊ិន ជនជាតិខ្មែរ បន្តដំណើរការ
រោងម៉ាស៊ីនកិនស្រូវកំលាំង ១៥ សេះ .................................................... ៣

០៦-១-៩៥ - ប្រកាសលេខ ១៦ ផក.ប្រក អនុញ្ញាតអោយលោក ស៊ុន ថៃ ជនជាតិខ្មែរ បន្តដំណើរការ
រោងម៉ាស៊ីនកិនស្រូវកំលាំង ១៦ សេះ .................................................... ៣

០៦-១-៩៥ - ប្រកាសលេខ ១៧ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី ឡាច លន់ ជនជាតិខ្មែរ បើកដំណើរការ
រោងម៉ាស៊ីនកិនស្រូវកំលាំង ១៦ សេះ .................................................... ៣

០៦-១-៩៥ - ប្រកាសលេខ ១៨ ផក.ប្រក អនុញ្ញាតអោយលោក រស់ ម៉ៅ ជនជាតិខ្មែរ បន្តដំណើរការ
រោងម៉ាស៊ីនកិនស្រូវកំលាំង ១៥ សេះ .................................................... ៣

០៦-១-៩៥ - ប្រកាសលេខ ១៩ ផក.ប្រក អនុញ្ញាតអោយលោក ធិម ឆោម ជនជាតិខ្មែរ បន្តដំណើរការ
រោងម៉ាស៊ីនកិនស្រូវកំលាំង ១៥ សេះ .................................................... ៣

០៦-១-៩៥ - ប្រកាសលេខ ២១ ផក.ប្រក អនុញ្ញាតអោយលោក ជួន ខាន់ ជនជាតិខ្មែរ បើកដំណើរការ
រោងម៉ាស៊ីនកិនស្រូវកំលាំង ៤០ សេះ .................................................... ៣

០៦-១-៩៥ - ប្រកាសលេខ ២២ ផក.ប្រក អនុញ្ញាតអោយលោក ឡាច តា ជនជាតិខ្មែរ បើកដំណើរការ
រោងម៉ាស៊ីនកិនស្រូវកំលាំង ៤០ សេះ .................................................... ៤

០៦-១-៩៥ - ប្រកាសលេខ ២៣ ផក.ប្រក អនុញ្ញាតអោយលោក លី វ៉ើ ជនជាតិខ្មែរ បើកដំណើរការ
រោងជាងជួសជុលរថយន្ត .................................................... ៣

០៦-១-៩៥ - ប្រកាសលេខ ២៤ ផក.ប្រក អនុញ្ញាតអោយលោក ម៉ាធី ជនជាតិខ្មែរ បើកដំណើរការ
រោងម៉ាស៊ីនកិនស្រូវកំលាំង ១២ សេះ .................................................... ៣

០៦-១-៩៥ - ប្រកាសលេខ ២៥ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី ប៉ាវ ឈុនណារី ជនជាតិខ្មែរ បើកដំណើរកា
ឧស្សាហកម្មតូចផលិតទឹកកកដើម .................................................... ៣

០៦-១-៩៥ - ប្រកាសលេខ ២៦ ផក.ប្រក អនុញ្ញាតអោយលោក ខេង ហួរ ជនជាតិខ្មែរ បើកដំណើរការ
ឧស្សាហកម្មតូចផលិតទឹកកកដើម .................................................... ៣

០៦-១-៩៥ - ប្រកាសលេខ ២៧ ផក.ប្រក អនុញ្ញាតអោយលោក ង៉ិល ធី ជនជាតិខ្មែរ បើកដំណើរការ
រោងម៉ាស៊ីនកិនស្រូវកំលាំង ១៦,៥ សេះ ............ ៣៥

០៦-១-៩៥ - ប្រកាសលេខ ២៨ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី ប៊ុន ណារី ជនជាតិខ្មែរ បើកដំណើរការ
សហគ្រាសកាត់ដេរសំលៀកសំពាក់ ............

០៦-១-៩៥ - ប្រកាសលេខ ២៩ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី ទូច ស្រួយ ជនជាតិខ្មែរ បន្តដំណើរការ
រោងម៉ាស៊ីនកិនស្រូវកំលាំង ១៨ សេះ ............ ៣៧

០៦-១-៩៥ - ប្រកាសលេខ ៣០ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី វ៉េង ឆៃនី ជនជាតិខ្មែរ បើកដំណើរការ
ឡផលិតឥដ្ឋ-ក្បឿង ............ ៣៧

០៦-១-៩៥ - ប្រកាសលេខ ៣១ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី ប៊ួ ធំម៉ា ជនជាតិខ្មែរ បើកដំណើរការ
រោងជាងតិនស្ពាន់ ............ ៣៨

០៦-១-៩៥ - ប្រកាសលេខ ៣២ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី ហួយ ហៀង ជនជាតិខ្មែរ បើកដំណើរការ
សិប្បកម្មកិនកាហ្វេ ............ ៣៨

០៦-១-៩៥ - ប្រកាសលេខ ៣៣ ផក.ប្រក អនុញ្ញាតអោយលោក លាង គី ជនជាតិខ្មែរ បើកដំណើរការ
ឡផលិតឥដ្ឋ-ក្បឿង ............ ៣៩

០៦-១-៩៥ - ប្រកាសលេខ ៣៤ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី វ៉ា តាវ ជនជាតិខ្មែរ បើកដំណើរការ
រោងជាងក្រឡឹងដែក ............ ៣៩

០៦-១-៩៥ - ប្រកាសលេខ ៣៥ ផក.ប្រក អនុញ្ញាតអោយអ្នកស្រីហា យន់ ជនជាតិខ្មែរ បើកដំណើរការ
រោងជាងក្រឡឹងដែក ............ ៣៩

០៦-១-៩៥ - ប្រកាសលេខ ៣៦ ផក.ប្រក អនុញ្ញាតអោយលោក គង់ នរុទ្ធិ ជនជាតិខ្មែរ បើកដំណើរការ
រោងផលិតឥដ្ឋពណ៌ ............

០៦-១-៩៥ - ប្រកាសលេខ ៣៧ ផក.ប្រក អនុញ្ញាតអោយលោក ទូច ឆៃ ជនជាតិខ្មែរ បន្តដំណើរការ
រោងម៉ាស៊ីនកិនស្រូវកំលាំង ១៦ សេះ ............ ៤០

០៦-១-៩៥ - ប្រកាសលេខ ៣៨ ផក.ប្រក អនុញ្ញាតអោយលោក ស ពី ជនជាតិខ្មែរ បើកដំណើរការ
រោងម៉ាស៊ីនកិនស្រូវកំលាំង ១៦ សេះ ............ ៤១

០៦-១-៩៥ - ប្រកាសលេខ ៣៩ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី ឆាយ ទៀង ជនជាតិខ្មែរ បន្តដំណើរការ រោងម៉ាស៊ីនកិនស្រូវកំលាំង ១៨ សេះ ........ ៤១

០៦-១-៩៥ - ប្រកាសលេខ ៤០ ផក.ប្រក អនុញ្ញាតអោយលោក ដូ តាត ជនជាតិខ្មែរ បើកដំណើរការ សិប្បកម្មផលិតសរសៃគុយទាវ ........

០៦-១-៩៥ - ប្រកាសលេខ ៤១ ផក.ប្រក អនុញ្ញាតអោយលោក ជាង យាងសេង ជនជាតិខ្មែរ បន្តដំណើរការ រោងម៉ាស៊ីនកិនស្រូវកំលាំង ២២ សេះ ........ ៤២

០៦-១-៩៥ - ប្រកាសលេខ ៤២ ផក.ប្រក អនុញ្ញាតអោយលោក ហោ សច្ចៈ ជនជាតិខ្មែរ បន្តបើកដំណើរការ ផលិតឥដ្ឋ-ក្បឿង ........ ៤៣

# ៤.ទីស្តីការរដ្ឋមន្ត្រី ក្រសួងពត៌មាន

## ប្រកាស

០៤-១-១៩៩៥ -ប្រកាសលេខ ០០៤/៩៥ ពម.ប្រក ស្តីពីការលុបឈ្មោះមន្ត្រីរាជការរបស់មន្ទីរពត៌មាន ខេត្ត កណ្តាល ........ ៤៤

០៥-១-១៩៩៥ -ប្រកាសលេខ ០០៥/៩៥ ពម.ប្រក ស្តីពីការយល់ព្រម និងទទួលស្គាល់មន្ត្រីរាជការ ៤៥

០៦-១-១៩៩៥ -ប្រកាសលេខ ០០៧/ ពម.ប្រក ស្តីពីការលុបឈ្មោះមន្ត្រីរាជការ ៤៦

០៦-១-១៩៩៥ -ប្រកាសលេខ ០០៨/ ពមប្រក ស្តីពីការលុបឈ្មោះមន្ត្រីរាជការ នៅមន្ទីរពត៌មាន រាជធានីភ្នំពេញ ........ ៤៧

# ៥.ទីស្តីការរដ្ឋមន្ត្រី ក្រសួងសុខាភិបាល

## ប្រកាស

០៥-១-១៩៩៥ -ប្រកាសលេខ ១៤ ស.គប ស្តីពីការប្តូរចនាសម្ព័ន្ធរដ្ឋបាលរបស់ការិយាល័យ សុខាភិបាលទីក្រុងកែប ........ ៤៨

# ៦.ទីស្តីការ ក្រសួងធម្មការ និងសាសនា

## ប្រកាស

០៤-១-១៩៩៥ -ប្រកាសលេខ ០៥/៩៥ កធស ស្តីពីការតែងតាំងមន្ត្រី រាជការ........ ៤៩

# I- ឯកសារគណៈរដ្ឋមន្ត្រី

## ១- អនុក្រឹត្យ

*រាជធានីភ្នំពេញ ,ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៩៥*

### អនុក្រឹត្យលេខ ០១ អនក្រ

ស្តីពីការលុបចោលអនុក្រឹត្យបង្កើតគណៈកម្មាធិការអចិន្ត្រៃយ៍ចំរុះអន្តរក្រសួង
ទប់ស្កាត់បទល្មើសព្រៃឈើបទល្មើសនេសាទបទល្មើសកាប់ដើមកៅស៊ូនិងដឹក
ជញ្ជូនជ័រកៅស៊ូ និង សេចក្តីសំរេចស្តីពីការបង្កើតគណៈកម្មការស្រាវជ្រាវត្រួត
ពិនិត្យបាតុភាពឈើមូល ឈើអារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែល ប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-យោងស្មារតីអង្គប្រជុំអន្តរក្រសួង ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៤

### សំរេច

**មាត្រា ១ :** លុបចោល

-អនុក្រឹត្យលេខ ០២ អនក្រ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៩៤ ស្តីពីការបង្កើតគណៈកម្មាធិការអចិន្ត្រៃយ៍ចំរុះ អន្តរក្រសួងទប់ស្កាត់បទល្មើសព្រៃឈើ បទល្មើសនេសាទ បទល្មើសកាប់ដើមកៅស៊ូ និង ដឹកជញ្ជូនជ័រកៅស៊ូ ។

-សេចក្តីសំរេចលេខ ៧៨ សសរ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការបង្កើតគណៈកម្មការស្រាវជ្រាវត្រួត ពិនិត្យឈើមូល ឈើអារ ។

-សេចក្តីសំរេចលេខ ៨៨ សសរ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសេចក្តីសំរេចលេខ ៧៨ សសរ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ។

**មាត្រា ២** : ប្រគល់ភារកិច្ចជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដើម្បីអនុវត្តតាមគោលការណ៍ថ្មី របស់រាជរដ្ឋាភិបាល និង អនុវត្តការងារទាំងឡាយដែលនៅសេសសល់ពីគណៈកម្មការស្រាវជ្រាវត្រួតពិនិត្យឈើមូល ឈើអារ ។ ក្នុងករណីចាំ បាច់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទអាចស្នើសុំកំលាំងរបស់ក្រសួងមានសមត្ថកិច្ច ដើម្បីចូលរួមក្នុងប្រតិ បត្តិការ ។

**មាត្រា ៣** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ សហប្រធាន គណៈកម្មការស្រាវជ្រាវត្រួតពិនិត្យឈើមូល ឈើអារ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុក អនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និងត្រា | ហត្ថលេខា និងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

***

*រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៩៥*

## អនុក្រឹត្យលេខ ០២ អនក្រ
## ស្តីពីការធ្វើនិយ័តភាពថវិកា ឆ្នាំ ១៩៩៤
## ពីជំពូក ១០ ទៅជំពូក ១១

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញច្បាប់ ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០១ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣

-បានឃើញច្បាប់ហិរញ្ញវត្ថុ សំរាប់ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០២ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣

-បានឃើញអនុក្រឹត្យលេខ ០១ អ.ន.ក្រ ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៩៤ ស្តីពីការបែងចែកឥណទានតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៤

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា ១ :** អនុញ្ញាតអោយធ្វើនិយ័តភាពថវិកាឆ្នាំ ១៩៩៤ ពីជំពូក ១០ ( បេឡាវត្សនិងប្រាក់បំណាច់ ) ចំនួនទឹកប្រាក់ ៥៩.៧៨៧. ១២៥រ,០០ ( ហាសិបប្រាំបួនលានប្រាំពីរយប៉ែតសិបប្រាំពីពាន់មួយរយម្ភៃប្រាំរៀលគត់ ) បញ្ចូលទៅជំពូក ១១ ( ដំណើរការ រដ្ឋបាល សំភារៈ និង ជួសជុលតូច ) សំរាប់ធ្វើការទូទាត់ថ្លៃទឹក ភ្លើងរបស់សាលាខេត្តបាត់ដំបង ។

**មាត្រា ២ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តបាត់ដំបង ត្រូវទទួលអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្តលេខា និងត្រា | ហត្ថលេខា និងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

***

*រាជធានីភ្នំពេញ ,ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៩៥*

# អនុក្រឹត្យលេខ ០៣ អនក្រ
# ស្តីពីប្រតិធិនឈប់សំរាកការងារ របស់មន្ត្រីរាជការ និយោជិត-កម្មករ ប្រចាំឆ្នាំ ១៩៩៥

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១-១១-១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់គណៈកម្មាធិការរៀបចំបុណ្យជាតិ អន្តរជាតិលេខ ៣២៥/៩៤ គបជម ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ១៩៩៤

## សំរេច

**មាត្រា ១** : អនុញ្ញាតអោយមន្ត្រីរាជការនិយោជិត កម្មករ នៃព្រះរាជាណាចក្រកម្ពុជាទាំងអស់ បានឈប់សំរាកការងារប្រចាំឆ្នាំ ១៩៩៥ តាមប្រតិទិនខាងក្រោម ÷

- ថ្ងៃ ០១ មករា : ទិវាចូលឆ្នាំសកល ០១ ថ្ងៃ
- ថ្ងៃ ០៨ មីនា : ទិវានារីអន្តរជាតិ ០១ ថ្ងៃ
- ថ្ងៃ ១៤-១៥-១៦ មេសា : បុណ្យចូលឆ្នាំខ្មែរ ០៣ ថ្ងៃ
- ថ្ងៃ ០១ ឧសភា : ទិវាពលកម្មអន្តរជាតិ ០១ ថ្ងៃ
- ថ្ងៃ ១៤ ឧសភា : បុណ្យវិសាខបូជា ០១ ថ្ងៃ
- ថ្ងៃ ១៨ ឧសភា : ពិធីច្រត់ព្រះនង្គ័ល ០១ ថ្ងៃ
- ថ្ងៃ ០១ មិថុនា : ទិវាកុមារអន្តរជាតិ ០១ ថ្ងៃ
- ថ្ងៃ ២៣-២៤-២៥ កញ្ញា : ភ្ជុំបិណ្ឌ ០៣ ថ្ងៃ
- ថ្ងៃ ២៤ កញ្ញា : ទិវាប្រកាសរដ្ឋធម្មនុញ្ញ ០១ ថ្ងៃ
- ថ្ងៃ ២៣ តុលា : ទិវាសន្ធិសញ្ញាសន្តិភាពកម្ពុជា នៅប៉ារីស ០១ ថ្ងៃ
- ថ្ងៃ ៣០-៣១ និង ០១ វិច្ឆិកា : បុណ្យចំរើនព្រះជន្មវស្សា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ០៣ ថ្ងៃ
- ថ្ងៃ ០៦-០៧-០៨ វិច្ឆិកា : បុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក ០៣ ថ្ងៃ
- ថ្ងៃ ០៩ វិច្ឆិកា : បុណ្យឯករាជ្យជាតិ ០១ ថ្ងៃ
- ថ្ងៃ ១០ ធ្នូ : ទិវាសិទ្ធិមនុស្ស ០១ ថ្ងៃ

មាត្រា ២ : ពេលវេលាឈប់ទាំងឡាយណា ដែលត្រូវចំថ្ងៃអាទិត្យ ត្រូវបានអនុញ្ញាតអោយឈប់សំរាក ០១ ថ្ងៃ នៃថ្ងៃបន្ទាប់ជា បន្ថែម ។

មាត្រា ៣ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៤ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការនៃគ្រប់រដ្ឋលេខាធិការដ្ឋាន ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្ថលេខា និង ត្រា | ហត្ថលេខា និងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

***

*រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៩៥*

## អនុក្រឹត្យលេខ ០៤ អនក្រ
## ស្តីពីការបង្កើត គណៈកម្មការជាតិ
## ទទួលបន្ទុកការងារជំនួយយោធាពីបរទេស

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាណាចក្រកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-យោងតាមសំណូមពរចាំបាច់ នៃកិច្ចសហប្រតិបត្តិការលើវិស័យយោធាជាមួយប្រទេសនានា ។

## សំរេច

មាត្រា ១ : បង្កើតគណៈកម្មការមួយហៅថា គណៈកម្មការជាតិទទួលបន្ទុកការងារជំនួយយោធាពីបរទេស ដើម្បីជួយដល់រាជរដ្ឋាភិបាល ក្នុងការបង្កើតកិច្ចសហប្រតិបត្តិការ និង ការទាក់ទងសុំជំនួយយោធាពីបរទេស ។

**មាត្រា ២** : សមាសភាព នៃគណៈកម្មការជាតិនេះរួមមាន ÷

-សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** នាយករដ្ឋមន្ត្រីទី ១ ជាសហប្រធាន

-សម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រីទី ២ ជាសហប្រធាន

-ឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី និងជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាអនុប្រធាន

-ឯកឧត្តម **គាត ឈន់** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអនុប្រធាន

-ឯកឧត្តម **ទៀ បាញ់** សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ជាអនុប្រធានអចិន្ត្រៃយ៍

-ឯកឧត្តម **ធា ចំរ៉ាត់** សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ជាអនុប្រធានអចិន្ត្រៃយ៍

-ឯកឧត្តម **យូ ហុកគ្រី** សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាសមាជិក

-ឯកឧត្តម **អ៊ុង ហួត** រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាសមាជិក

-ឯកឧត្តម ឧត្តមសេនីយឯក **កែ គឹមយ៉ាន** នាយអគ្គសេនាធិការ កងយោធពលខេមរភូមិន្ទ

ជាសមាជិក

-ឯកឧត្តម **ស៊ុំ ម៉ានិត** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិក

-ឯកឧត្តម **ឯក សេរីវឌ្ឍ** រដ្ឋលេខាធិការក្រសួងការពារជាតិ ជាសមាជិកអចិន្ត្រៃយ៍

-ឯកឧត្តម ឧត្តមសេនីយ៍ **មាស់ វៀម** ទីប្រឹក្សាយោធាសម្តេចនាយករដ្ឋមន្ត្រីទី ២

ជាសមាជិកអចិន្ត្រៃយ៍

-ឯកឧត្តម ឧត្តមសេនីយ៍ **ធុំ សម្បូរ** ទីប្រឹក្សាយោធាសម្តេចនាយករដ្ឋមន្ត្រីទី ១

ជាសមាជិកអចិន្ត្រៃយ៍

**មាត្រា ៣** : គណៈកម្មការជាតិនេះ មានភារកិច្ច ÷

-ចាត់ចែងទាក់ទងជាមួយប្រទេសនានា ក្នុងន័យពង្រីកកិច្ចសហប្រតិបត្តិការលើវិស័យយោធា និង ទាក់ទងសុំជំនួយ យោធាពីបរទេស ។

-ពិនិត្យពិភាក្សា និង កែសំរួលអោយបានសមស្របតាមសភាពការណ៍ជាក់ស្តែងនូវគំរោងស្នើសុំជំនួយយោធាពីបរ ទេស ដែលបានលើកឡើងដោយក្រសួងការពារជាតិ ។

-ពិនិត្យតាមដាន និង បង្កលក្ខណៈងាយស្រួល អោយក្រសួងការពារជាតិបានទទួល និង ប្រើប្រាស់ប្រកបដោយ ប្រសិទ្ធភាព នូវជំនួយយោធាពីបរទេស ។

-កសាងរបៀបរបបធ្វើការងារផ្ទាល់របស់ខ្លួន ដើម្បីចាត់ចែងការងារអោយមានប្រសិទ្ធភាព ។

**មាត្រា ៤ :** គណៈកម្មការពិគ្រោះការងារ ដើម្បីពង្រីកកិច្ចសហប្រតិបត្តិការជាមួយភាគីបារាំង ដែលត្រូវបានចាត់តាំងឡើងតាម សេចក្ដីសំរេចលេខ ២២ សសរ ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ១៩៩៣ គណៈកម្មការសំរាប់ធ្វើការជាមួយនាយទាហានសេនាធិការ នៃបេសកកម្មរបស់រដ្ឋាភិបាលសាធារណរដ្ឋបារាំង ដែលត្រូវបានចាត់តាំងឡើងដោយសេចក្ដីសំរេចលេខ ២១ សសរ ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ១៩៩៣ ដោយរដ្ឋាភិបាលជាតិបណ្ដោះអាសន្ននៃកម្ពុជា និងក្រុមការងារចំរុះ ខ្មែរ-បារាំង ដែលត្រូវបានចាត់តាំងឡើង ដោយសេចក្ដីសំរេចលេខ ២៧ សសរ ចុះថ្ងៃទី ១៤ ខែ មិនា ឆ្នាំ ១៩៩៤ ត្រូវបាន បញ្ចប់ភារកិច្ចរបស់ខ្លួន ។ រាល់ការងារទាក់ទងនឹងកិច្ចសហប្រតិបត្តិការជាមួយភាគីបារាំង ត្រូវបានគណៈកម្មការជាតិ ដែល បង្កើតឡើងនេះ ទទួលរ៉ាប់រងបន្ត ។

**មាត្រា ៥ :** ដើម្បីជាជំនួយកិច្ចការដល់គណៈកម្មការជាតិនេះ លេខាធិការដ្ឋានមួយ ត្រូវបានបង្កើតឡើងរួមមានសមាសភាព ÷

- -ឯកឧត្ដម **ឯក សេរីវឌ្ឍ** រដ្ឋលេខាធិការក្រសួងការពារជាតិ ជាប្រធាន
- -ឧត្ដមសេនីយ៍ **ស៊ី ស៊ិនកិច** ទីប្រឹក្សាក្រសួងការពារជាតិ ជាអនុប្រធានអចិន្ត្រៃយ៍
- -ឧត្ដមសេនីយ៍ **ប្រាក់ ម៉ារឌី** ឧទ្ទកាល័យក្រសួងការពារជាតិ ជាអនុប្រធានអចិន្ត្រៃយ៍
- -ឧត្ដមសេនីយ៍ **ឡាយ ម៉ិនសុខ** ឧទ្ទកាល័យក្រសួងការពារជាតិ ជាសមាជិកអចិន្ត្រៃយ៍
- -លោកស្រី **យូ អយ** ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាសមាជិកអចិន្ត្រៃយ៍
- -ឧត្ដមសេនីយ៍ **សរ សុខុន** ការិយាល័យជំនួយបរទេស ( នាយកដ្ឋានភស្តុភារក្រសួងការពារជាតិ ) ជាសមា ជិកអចិន្ត្រៃយ៍
- -ឧត្ដមសេនីយ៍ **ចាយ គីមម៉ិច** ឧទ្ទកាល័យអគ្គសេនាធិការ ជាសមាជិកអចិន្ត្រៃយ៍
- -ឧត្ដមសេនីយ៍ **ពាក សុខ** ក្រុមផែនការ អគ្គសេនាធិការ ជាសមាជិកអចិន្ត្រៃយ៍
- -លោក **សយ សុខា** តំណាងទីស្ដីការគណៈរដ្ឋមន្ត្រី ជាសមាជិក

**មាត្រា ៦ :** លេខាធិការដ្ឋាន នៃគណៈកម្មការជាតិនេះ អាចយកនាយកដ្ឋានទាក់ទងអន្តរជាតិនៃក្រសួងការពារជាតិ ធ្វើជាទីស្នាក់ការដើម្បីបំពេញការងារក្នុងពេលចាំបាច់ ។

**មាត្រា ៧ :** សហរដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ នាយអគ្គសេនាធិការនៃ កងយោធពលខេមរភូមិន្ទ និង ឯកឧត្តមអស់ លោកដែលមានឈ្មោះដូចបាន ចែងខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យ នេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

***

*រាជធានីភ្នំពេញ , ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ១៩៩៥*

## អនុក្រឹត្យលេខ ០១ អនក្រ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើត និង ប្រើប្រាស់មេដាយស្ថាបនាជាតិ និងប័ណ្ណស្ថាបនាជាតិ
- បានឃើញគុណបំណាច់របស់សប្បុរសជនក្នុងការជួយរួមចំណែកសង្គ្រោះប្រជារាស្ត្រក្រីក្រ

## សំរេច

**មាត្រា ១ :** ត្រូវបានប្រគល់មេដាយស្ថាបនាជាតិតាមលំដាប់ថ្នាក់ ជូនចំពោះសប្បុរសជន ដែលមានសទ្ធាជ្រះថ្លាបានបរិច្ចាគ ទ្រព្យសម្បត្តិ ចូលរួមជួយសង្គ្រោះប្រជារាស្ត្រក្រីក្រចំនួន ២.០០០ គ្រួសារ ដូចមានរាយនាមខាងក្រោម ÷

**ក.ជូនមេដាយស្ថាបនាជាតិថ្នាក់លេខ ១ :**

១_លោក SUCHIN CHINTANA ប្រធានអគ្គនាយកក្រុមហ៊ុនពិភពពាណិជ្ជកម្ពុជា ទឹកប្រាក់ US$២០,០០០

២_លោកស្រី SUDAWAN RANGNOK TAI អនុប្រធានអគ្គនាយកក្រុមហ៊ុនពិភពពាណិជ្ជកម្ពុជា ទឹកប្រាក់ US$១២,០០០

**ខ.ជូនមេដាយស្ថាបនាជាតិថ្នាក់លេខ ២ :**

១_លោក LAIKIM TONG អគ្គនាយកក្រុមហ៊ុនពិភពពាណិជ្ជកម្ពុជា ទឹកប្រាក់ US$៨,០០០

**មាត្រា ២ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អប្រសើរ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

***

# ២. សេចក្តីសំរេច

*រាជធានីភ្នំពេញ ,ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៩៥*

## សេចក្តីសំរេចលេខ ០១ សសរ
## ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង សំរាប់ ការពារនិង សាងសង់ស្ថានីយ៍ថាមពលអគ្គិសនីនៅគីរីរម្យ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តមសីហនុ វរ្ម័ន ព្រះមហាក្សត្រនៃ

-បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ២៤-៩-៩៤ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២

-អនុលោមតាមសេចក្តីជូនដំណឹងលេខ ១៩៨០ សជណ.សរ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីលទ្ធផលសម័យប្រជុំអន្តរក្រសួងកាលពីថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤

-ផ្អែកតាមតំរូវការចាំបាច់ក្នុងការការពារ និងសាងសង់វារីអគ្គិសនីនៅគិរីរម្យ

## សំរេច

**ប្រការ ១ :** បង្កើតគណៈកម្មការអន្តរក្រសួងសំរាប់ការពារ និងសាងសង់ស្ថានីយ៍វារីអគ្គិសនីនៅគិរីរម្យ ដែលមានសមាសភាព ដូចខាងក្រោម :

១-ឯកឧត្តម ពូ សុធីរៈ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ប្រធាន

២-ឯកឧត្តម ឧត្តមសេនីយ៍ ឯម សំអាន រដ្ឋលេខាធិការក្រសួងមហាផ្ទៃ អនុប្រធាន

៣-ឯកឧត្តម ឧត្តមសេនីយ៍ ក្រូច យឿម អនុរដ្ឋលេខាធិការក្រសួងការពារជាតិ អនុប្រធាន

៤-ឯកឧត្តម ឧត្តមសេនីយ៍ ប៉ាន់ ថៃ នាយករងអគ្គសេនាធិការ សមាជិក

៥-ឯកឧត្តម ជិន គិមស្រេង អនុរដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន សមាជិក

៦-ឯកឧត្តម សាម៉ី បាចា អនុរដ្ឋលេខាធិការក្រសួងគ្រប់គ្រងបរិដ្ឋាន សមាជិក

៧-ឯកឧត្តម ឈៀង យ៉ានណារ៉ា អគ្គលេខាធិការ គ.ជ.នា សមាជិក

៨-លោក អ៊ុំ ស៊ុម អភិបាលរងទី ២ នៃខេត្តកំពង់ស្ពឺ សមាជិក

៩-លោក ឡៅ ម៉ុងហៃ អនុប្រធានមជ្ឈមណ្ឌលមីននៅកម្ពុជា CMAC សមាជិក

១០-លោក លីម គានហោ ប្រធាននាយកដ្ឋានធារាសាស្ត្រឧតុនិយមនិងជលសាស្ត្រ សមាជិក

១១-លោក ឆេព ឌុក្លា អនុប្រធាននាយកដ្ឋានឧស្សាហកម្មនៃទីស្តីការគណៈរដ្ឋមន្ត្រីសមាជិក

១២-លោក លីម លូអ៊ី អនុប្រធាននាយកដ្ឋានសំណង់នៃក្រសួងផែនការ សមាជិក

១៣-លោក កាំង លាងខំណ្ឌ នាយកទ្រព្យសម្បត្តិរដ្ឋនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

១៤-លោក ស៊ិន និនិ តំណាងគណៈកម្មការជាតិទន្លេមេគង្គ សមាជិក

១៥-លោក ញ៉ឹក ប្រ៊ីច ប្រធាននាយកដ្ឋានថាមពលនៃក្រសួងឧស្សាហកម្មរ៉ែនិងថាមពល លេខាធិការអចិន្ត្រៃយ៍

ប្រការ ២ : គណៈកម្មការនេះមានភារកិច្ច :

_ទទួលខុសត្រូវក្នុងការធានានិងរក្សាសន្តិសុខដល់ការដ្ឋាន ។

_សហការយ៉ាងជិតស្និទ្ធ និង ធ្វើការសម្របសម្រួលជាមួយភាគីប្រទេសផ្តល់ជំនួយ សំដៅរើកវិធាន ការការងារ និងបង្កលក្ខណៈងាយស្រួលដើម្បីឱ្យការជួសជុល និងសាងសង់វារីអគ្គិសនីនៅគីរីរម្យ ប្រព្រឹត្តទៅតាមការគ្រោងទុក និងមានប្រសិទ្ធភាពខ្ពស់ ។

_ពិនិត្យ និង អនុម័តលើគំរោងការកម្មវិធី ការបំពេញបែបបទទាំងឡាយឱ្យបានខ្លី និងឆាប់បំផុត ដើម្បីអោយការអនុវត្តន៍គំរោងផែនការជួសជុល និងសាងសង់វារីអគ្គិសនីនៅគីរីរម្យ មានដំណើរ ការល្អប្រសើរនិងជៀសវាងបាននូវការ រាំងស្ទះ ។

_ជំរុញនិងតាមដានការអនុវត្តនូវបណ្តាវិធានការ និង គោលការណ៍ទាំងឡាយរបស់ គណៈកម្មការអន្តរ ក្រសួង និង រាជរដ្ឋាភិបាលបានដាក់ចុះ ។

_ ធ្វើរបាយការណ៍ឱ្យបានទៀងទាត់ នៅរៀងរាល់បំណាច់ខែជូនរាជរដ្ឋាភិបាលស្តីពី សកម្មភាពការអភិវឌ្ឍន៍ នៃសកម្មភាពរបស់គណៈកម្មការអន្តរក្រសួង សកម្មភាពរបស់ភាគីប្រទេសផ្តល់ជំនួយ និងលទ្ធផល ដែលសំរេចបានក្នុងការជួសជុល និងសាងសង់វារីអគ្គិសនីនៅគីរីរម្យ ។

_នៅក្នុងការអនុវត្តភារកិច្ច ប្រសិនបើនៅពេលជួបបញ្ហាលំបាកស្មុគស្មាញខ្លាំងគណៈកម្មការអន្តរ ក្រសួងត្រូវធ្វើរបាយការណ៍ឬលើកយកបញ្ហាជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងដោះស្រាយ ។

ប្រការ ៣ : សមាជិកគណៈកម្មការអន្តរក្រសួង ត្រូវចូលរួមប្រជុំ និងអនុវត្តការងារតាមការណែនាំ របស់ប្រធាន ។

_គណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ។

_ទីចាត់ការ យកទីស្តីការក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ធ្វើជាមជ្ឈមណ្ឌលអចិន្ត្រៃយ៍ ដើម្បីសំរប សំរួល និង ទំនាក់ទំនងការងាររបស់គណៈកម្មការអន្តរក្រសួង និងជាមួយភាគីប្រទេសផ្តល់ជំនួយ ។

ប្រការ ៤ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួង មហាផ្ទៃនិង សន្តិសុខជាតិ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួង សាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួង កសិកម្មរុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងផែនការរដ្ឋមន្ត្រី ក្រសួងបរិស្ថាន ប្រធានគណៈកម្មការជាតិទន្លេមេគង្គ ប្រធានមជ្ឈមណ្ឌលសកម្មភាព មីននៅកម្ពុជា ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អភិបាលខេត្តកំពង់ស្ពឺ និងឯកឧត្តម អស់លោកដូច

មាននាមនៅក្នុងប្រការ ១ មានភារកិច្ចអនុវត្តតាមសេចក្តីសំរេចនេះ ។ សេចក្តីសំរេចនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

***

*រាជធានីភ្នំពេញ ,ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៩៥*

# សេចក្តីសំរេចលេខ ០២ សសរ
# ស្តីពីការបង្កើតអនុគណៈកម្មាធិការរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ខេត្តពោធិសាត់

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញសេចក្តីសំរេចលេខ ៣៤ សសរ ចុះថ្ងៃទី ១៨ តុលា របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតគណៈកម្មាធិការជាតិរៀបចំទឹកដី និង គោលការណ៍នគរូបនីយកម្មសំរាប់តំបន់ ជុំវិញភ្នំពេញ និងខេត្ត ក្រុង ទូទាំងប្រទេស

-បានឃើញសេចក្តីសំរេចលេខ ១៣ សសរ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៤ ស្តីពីការកែប្រែសមាសភាព នៃគណៈកម្មាធិការជាតិរៀបចំទឹកដី និង គោលការណ៍នគរូបនីយកម្ម

-បានឃើញច្បាប់ស្តីពីការរៀបចំទឹកដីនគរូបនីយកម្ម និង សំណង់ដែលរដ្ឋសភាជាតិបានអនុម័តកាលពីថ្ងៃទី ២៤ ឧសភា ឆ្នាំ ១៩៩៤ នាសម័យប្រជុំរដ្ឋសភាលើកទី ២ នីតិកាលទី ១

-បានឃើញដីកាស្តីពីការបង្កើតគណៈកម្មាធិការរៀបចំទឹកដីនគរូបនីយកម្ម និង សំណង់ខេត្តពោធិសាត់លេខ ០១៩៤ ដ.គ.រាស ចុះថ្ងៃទី ១៤ ធ្នូ ឆ្នាំ ១៩៩៤

-ផ្អែកតាមសំណូមពរការងារចាំបាច់

## សំរេច

**ប្រការ ១ :** ត្រូវបានបង្កើតអនុគណៈកម្មាធិការរៀបចំទឹកដីនគរូបនីយកម្ម និង សំណង់ខេត្តពោធិសាត់ ។

**អនុគណៈកម្មាធិការនេះមានសមាសភាពដូចតទៅ :**

១_ឯកឧត្តម អភិបាលខេត្ត ជាប្រធាន

២_ឯកឧត្តម អភិបាលខេត្តរងទី ១ ជាសមាជិកអចិន្ត្រៃយ៍

៣_លោក នាយកមន្ទីរសាធារណការខេត្ត ជាសមាជិក

៤_លោក នាយកមន្ទីរកសិកម្មខេត្ត ជាសមាជិក

៥_លោក ប្រធានការិយាល័យសុរិយោដីខេត្ត ជាសមាជិក

៦_លោក នាយកមន្ទីរទេសចរណ៍ខេត្ត ជាសមាជិក

៧_លោក ប្រធានមន្ទីរគ្រប់គ្រងបរិដ្ឋានខេត្ត ជាសមាជិក

៨_លោក អភិបាលទីរួមខេត្តពោធិសាត់ ជាសមាជិក

៩_លោក ប្រធានការិយាល័យសំណង់ខេត្ត ជាសមាជិកនិងលេខាធិការ

**ប្រការ ២ :** ភារកិច្ចរបស់អនុគណៈកម្មាធិការអនុវត្តដូចប្រការ ២ នៃសេចក្តីសំរេចលេខ ៣៤ សសរ ចុះថ្ងៃទី ១៨ តុលា ឆ្នាំ ១៩៩៣ ។

**ប្រការ ៣ :** អនុគណៈកម្មាធិការនេះត្រូវមានលេខាធិការដ្ឋានមួយដែលមានទីស្នាក់ការនៅសាលាខេត្ត និង ដឹកនាំដោយឯកឧត្តមអភិបាលខេត្តរងទី ១ ទទួលបន្ទុកអចិន្ត្រៃយ៍ ។

**ប្រការ ៤ :** ការប្រើប្រាស់ក្របខ័ណ្ឌ ត្រូវយកអ្នកបច្ចេកទេសអាស្រ័យដោយខេត្តចាត់ចែងតាមតំរូវការ ។

**ប្រការ ៥ :** អនុគណៈកម្មាធិការនេះមានសិទ្ធិប្រើប្រាស់ត្រាសាលាខេត្ត សំរាប់ជាផ្លូវការ ។

**ប្រការ ៦ :** សមាជិកអនុគណៈកម្មាធិការរៀបចំទឹកដីនគរូបនីយកម្ម និងសំណង់ខេត្តពោធិសាត់មានភារកិច្ចអនុវត្តសេចក្តី សំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ប្រធាន

ហត្ថលេខា និង ត្រា

**ខណ្ណ ម៉ូលីខណ្ណ**

**ទេសរដ្ឋមន្ត្រី**

*រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៩៥*

# សេចក្តីសំរេចលេខ ០៣ សសរ
## ស្តីពីការបង្កើតអនុគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ខេត្តកំពង់ចាម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញសេចក្តីសំរេចលេខ ៣៤ សសរ ចុះថ្ងៃទី ១៨ តុលា ឆ្នាំ ១៩៩៣ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតគណៈកម្មាធិការជាតិរៀបចំទឹកដី និង គោលការណ៍នគរូបនីយកម្មសំរាប់ តំបន់ជុំវិញភ្នំពេញ និង ខេត្ត ក្រុង ទូទាំងប្រទេស
- បានឃើញសេចក្តីសំរេចលេខ ១៣ សសរ ចុះថ្ងៃទី ១៥ កុម្ភៈ ឆ្នាំ ១៩៩៤ ស្តីពីការកែប្រែ សមាសភាពនៃគណៈកម្មាធិការជាតិរៀបចំទឹកដី និង គោលការណ៍នគរូបនីយកម្ម
- បានឃើញច្បាប់ស្តីពីការរៀបចំទឹកដីនគរូបនីយកម្ម និង សំណង់ដែលរដ្ឋសភាជាតិ បានអនុម័តកាលពីថ្ងៃទី ២៤ ឧសភា ឆ្នាំ ១៩៩៤ នាសម័យប្រជុំរដ្ឋសភាលើកទី ២ នីតិកាលទី ១
- បានឃើញលិខិតស្នើសុំបង្កើតអនុគណៈកម្មាធិការរៀបចំទឹកដីនគរូបនីយកម្ម និង សំណង់ ខេត្តកំពង់ចាម លេខ ៤៣២ ជខ កច ចុះថ្ងៃទី ១៥ ធ្នូ ឆ្នាំ ១៩៩៤
- [illegible]

[illegible]

[illegible]

[illegible]

[illegible]

៣. លោក ប្រធាន [illegible]

៤. លោក ប្រធាន [illegible]

៥. លោក ប្រធាន [illegible]

[illegible]

[illegible] ប្រធាន [illegible]

៨_លោក ប្រធាន មន្ទីរផែនការខេត្ត ជាសមាជិកនិងលេខាធិការ

**ប្រការ ២ :** ភារកិច្ចរបស់អនុគណៈកម្មាធិការអនុវត្តដូចប្រការ ២ នៃសេចក្តីសំរេចលេខ ៣៤ សសរ ចុះថ្ងៃទី ១៨ តុលា ឆ្នាំ ១៩៩៣ ។

**ប្រការ ៣ :** អនុគណៈកម្មាធិការនេះត្រូវមានលេខាធិការដ្ឋានមួយ ដែលមានទីស្នាក់នៅសាលាខេត្ត និងដឹកនាំដោយឯកឧត្តម អភិបាលខេត្តរងទី ១ ទទួលបន្ទុកអចិន្ត្រៃយ៍ ។

**ប្រការ ៤ :** ការប្រើប្រាស់ក្របខ័ណ្ឌ ត្រូវយកអ្នកបច្ចេកទេសរាស្រ័យដោយខេត្តចាត់ចែងតាមតំរូវការ ។

**ប្រការ ៥ :** អនុគណៈកម្មាធិការនេះមានសិទ្ធិប្រើប្រាស់ត្រាសាលាខេត្ត សំរាប់ជាផ្លូវការ ។

**ប្រការ ៦ :** សមាជិកអនុគណៈកម្មាធិការរៀបចំទឹកដីនគរូបនីយកម្ម និងសំណង់ខេត្តកំពង់ចាម មានភារកិច្ច អនុវត្តសេចក្តី សំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ប្រធាន

ហត្ថលេខា និង ត្រា

**ចណ្ឌ ម៉ូលីចណ្ឌ**

**ទេសរដ្ឋមន្ត្រី**

***

*រាជធានីភ្នំពេញ ,ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៩៥*

## សេចក្តីសំរេចលេខ ០៤ ស.ស.រ
## ស្តីពីការបង្កើតអនុគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញសេចក្តីសំរេចលេខ ៣៤ សសរ ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៩៣ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំទឹកដីនគរូបនីយកម្ម និងសំណង់

-បានឃើញសេចក្តីសំរេចលេខ ១៣ សសរ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ១៩៩៤ របស់រាជរដ្ឋាភិបាល ស្តីពីការកែប្រែសមាសភាពគណៈកម្មាធិការជាតិរៀបចំទឹកដីនគរូបនីយកម្ម និង សំណង់

-បានឃើញច្បាប់ស្តីពីការរៀបចំទឹកដីនគរូបនីយកម្ម និងសំណង់ដែលសភាជាតិបានអនុម័តកាលពីថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ១៩៩៤ នាសម័យប្រជុំរដ្ឋសភាលើកទី ២ នីតិកាលទី ១

-បានឃើញលិខិតលេខ ១១៨ ស.ណ ចុះថ្ងៃទី ១៥ ធ្នូ ឆ្នាំ ១៩៩៤ របស់សាលាខេត្តព្រះវិហារ ស្តីពីការស្នើសុំ បង្កើតអនុគណៈកម្មាធិការរៀបចំទីកដីនគូបនីយកម្ម និងសំណង់ខេត្ត ព្រះវិហារ

**សំរេច**

**ប្រការ ១ :** ត្រូវបានបង្កើតអនុគណៈកម្មាធិការរៀបចំទឹកដីនគូបនីយកម្ម និងសំណង់ខេត្តព្រះវិហារ ។

**អនុគណៈកម្មាធិការនេះមានសមាសភាពដូចតទៅ ÷**

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **មៀន សារិន** | អភិបាលខេត្ត | ជាប្រធាន |
| ២-ឯកឧត្តម | **ស៊ីុខ អ៊ាន** | អភិបាលខេត្តរងទី ២ | ជាសមាជិកអចិន្ត្រៃយ៍ |
| ៣-លោក | **ម៉ី ម៉ិច** | អនុប្រធានមន្ទីរកសិកម្មខេត្ត | ជាសមាជិក |
| ៤-លោក | **ខៀវ ដារី** | ប្រធានការិយាល័យសុរិយោដី | ជាសមាជិក |
| ៥-លោក | **ជាន់ សំអាន** | ប្រធានមន្ទីរសាធារណៈការខេត្ត | ជាសមាជិក |
| ៦-លោក | **ថូ ម៉ិនថៃ** | ប្រធានមន្ទីរទេសចរណ៍ខេត្ត | ជាសមាជិក |
| ៧-លោក | | ប្រធានមន្ទីរបរិដ្ឋានខេត្ត | ជាសមាជិក |
| ៨-លោក | **ប្រិយ សយ** | ប្រធានមន្ទីរផែនការ | ជាសមាជិក |

**ប្រការ ២ :** ភារកិច្ចរបស់អនុគណៈកម្មាធិការ អនុវត្តដូចប្រការ ២ នៃសេចក្តីសំរេចលេខ ៣៤ សសរ ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៩៣ ។

**ប្រការ ៣ :** អនុគណៈកម្មាធិការនេះ ត្រូវមានលេខាធិការដ្ឋានមួយដែលមានទីស្នាក់ការនៅសាលាខេត្ត និង ដឹកនាំដោយឯកឧត្តម អភិបាលខេត្តរងទី ២ ទទួលបន្ទុកអចិន្ត្រៃយ៍ ។

**ប្រការ ៤ :** ការប្រើប្រាស់ក្របខ័ណ្ឌត្រូវយកអ្នកបច្ចេកទេសអាស្រ័យដោយខេត្តចាត់ចែងតាមតម្រូវការ ។

**ប្រការ ៥ :** អនុគណៈកម្មាធិការនេះមានសិទ្ធប្រើប្រាស់ត្រារបស់សាលាខេត្ត សំរាប់ជាផ្លូវការ ។

**ប្រការ ៦ :** សមាជិកអនុគណៈកម្មាធិការរៀបចំទឹកដីនគូបនីយកម្ម និងសំណង់ខេត្តព្រះវិហារ មានភារកិច្ចអនុវត្តសេចក្តី សំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ប្រធាន

ហត្ថលេខា និង ត្រា

**ចណ្ឌ ម៉ូលីចណ្ឌ**

**ទេសរដ្ឋមន្ត្រី**

*រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មករា ឆ្នាំ ១៩៩៥*

## សេចក្ដីសំរេចលេខ ០៥ សសរ
## ស្ដីពីនីតិវិធីថ្មីក្នុងការនាំចេញឈើមូល
## ឈើអារ និង ឈើកែច្នៃចៅបរទេស

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញក្រឹត្យច្បាប់លេខ ៣៥ ក្រ.ច ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ១៩៨៨ ស្ដីពីការគ្រប់គ្រងវិស័យព្រៃឈើ
- យោងតាមស្មារតីនៃអង្គប្រជុំអន្តរក្រសួងនៅថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ១៩៩៤

### សំរេច

**ប្រការ ១ :** លុបនិតិវិធីនិងបែបបទនៃការនាំឈើចេញ ដែលមានចែងក្នុងសេចក្ដីសំរេចលេខ ៦៥ សសរ ចុះថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ១៩៩៤ ។

**ប្រការ ២ :** ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ត្រូវកសាងផែនការនាំចេញឈើមូល ឈើអារ និងឈើកែច្នៃប្រចាំឆ្នាំ ។ គំរោងផែនការនេះ ត្រូវតាក់តែងឡើងដោយឈរលើមូលដ្ឋាននៃការប្រើប្រាស់ឈើដ៏មានប្រសិទ្ធភាព ស្ថិតស្ថេរយូរអង្វែង ធានានូវនយោបាយស្មេរភាពរូបនីយកម្មសេដ្ឋកិច្ចជាតិ នយោបាយគ្រប់គ្រងបរិដ្ឋាន និងត្រូវផ្ដើមចេញពីកិច្ចព្រមព្រៀងផ្លាស់ប្ដូរទំនិញ និង កិច្ចសន្យាវិនិយោគទុនមាន ព្រៃសម្បទាន ព្រៃគុប រោងចក្រអារឈើ រោងចក្រកែច្នៃឈើ និងគោលដៅផ្សេងៗ ។ កំរិតកំណត់ផែនការនេះត្រូវដាក់ជូនគណៈរដ្ឋមន្ត្រីអនុម័ត ហើយគឺជាឧបសម្ព័ន្ធមួយនៃផែនការចំណូលថវិការដ្ឋសំរាប់ឆ្នាំសារពើព័ន្ធនិមួយៗ ។

**ប្រការ ៣ :** ចំពោះករណីឈើមូល ឈើអារ និងឈើកែច្នៃក្រៅកំរិតកំណត់ផែនការ ត្រូវសុំការអនុញ្ញាតនាំចេញពីរាជរដ្ឋាភិបាល ។

**ប្រការ ៤ :** ចំពោះករណីឈើមូល ឈើអារ និងឈើកែច្នៃដែលធ្វើអាជីវកម្មខុសច្បាប់ដែលរដ្ឋកំណត់ត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋ ។

**ប្រការ ៥**: រាល់ប្រាក់ចំណូលដែលបានពីការបង់ថ្លៃឈើឈរ ពន្ធនាំចេញ និងពីការលក់និងនាំចេញឈើហ្លួង ឈើអារនិងឈើកែច្នៃ ឈើរីបអូស ព្រមទាំងកំរៃផ្សេងៗ ត្រូវបង់ចូលរតនាគារទាំងអស់ ។

**ប្រការ ៦** : អាជីវករ ឬអ្នកនាំចេញត្រូវយកប័ណ្ណចំណូលពីរតនាគារទៅបង្ហាញដល់នាយកដ្ឋានរុក្ខាប្រមាញ់ ទីចាត់ការគយ និង ក្រសួងពាណិជ្ជកម្ម ។

**ប្រការ ៧** : លើរាល់លិខិតស្នើសុំនាំចេញត្រូវចុះហត្ថលេខាដោយរដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។ នាយកដ្ឋានរុក្ខាប្រមាញ់មានភារកិច្ចចុះហត្ថលេខាលើអាជ្ញាប័ណ្ណនាំចេញ ក្នុងឋានៈជាអ្នកនាំចេញ ឬ ជាអ្នកជួយនាំចេញ ក្រោយពេលពិនិត្យឃើញមានឈើជាក់ស្តែងតាមសំណើ ទាំងខាងបរិមាណ ទាំងខាងគុណភាព ។

**ប្រការ ៨** : ក្រសួងពាណិជ្ជកម្មមានភារកិច្ចចេញអាជ្ញាប័ណ្ណនាំចេញឈើហ្លួង ឈើអារនិងឈើច្នៃ ផ្តល់អោយអ្នកនាំចេញ និងចេញវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើម ( ......................... ) ក្រោយពីបានឃើញនូវប័ណ្ណចំណូលពី រតនាគារឬពីធនាគារជាតិនិងសេចក្តីបញ្ជាក់ត្រួតពិនិត្យរបស់គយ ។

**ប្រការ ៩** : ទីចាត់ការគយ និងរដ្ឋាករ ត្រូវមានភារកិច្ចចុះត្រួតពិនិត្យនៅតាមមាត់ច្រកដែលត្រូវបានទទួលការអនុញ្ញាតឱ្យប្រគល់ ឈើហ្លួង ឈើអារ និងឈើកែច្នៃនាំចេញ និងធ្វើការកត់ត្រាបញ្ជាក់លើខ្នងអាជ្ញា [illegible] ឈើអារ ឬឈើកែច្នៃដែលបានអនុញ្ញាតនាំចេញហើយ [illegible] ក្រសួងកសិកម្ម [illegible] [illegible] ។

**ប្រការ ១០** [illegible] ឈើហ្លួង ឬ ឈើអារ ឬ ឈើកែច្នៃនាំចេញ មាន :

- [illegible]
- [illegible]
- [illegible] ដែលមានកំណត់ក្នុងកិច្ចព្រមព្រៀងស្តីពីការបើកមាត់ច្រក រវាង [illegible] [illegible] ឬ [illegible] ។
- [illegible] ។

នៅរាល់គ្រប់មាត់ច្រកដែលអនុញ្ញាតអោយនាំចេញត្រូវមានដាក់ទីតាំងបុស្តិ៍គយប្រចាំការ ។

ប្រការ ១១ : ចំពោះការសុំនាំចេញឈើមូល ឬ ឈើអារ ឬ ឈើកែច្នៃឆ្លងកាត់(.........) ប្រទេសជិតខាងណាដែលមានកិច្ចព្រមព្រៀងទ្វេភាគី ត្រូវប្រើប្រាស់អាជ្ញាប័ណ្ណនាំចេញឆ្លងកាត់ដែលចេញដោយក្រសួងពាណិជ្ជកម្ម ។ ចំពោះប្រទេសណា ដែលពុំទាន់មានកិច្ចព្រមព្រៀងទំនិញឆ្លងកាត់ទ្វេភាគីនៅឡើយ អ្នកនាំចេញត្រូវធ្វើលិខិតស្នើទៅក្រសួងការបរទេសនិង សហប្រតិបត្តិការអន្តរជាតិតាមរយៈក្រសួងពាណិជ្ជកម្ម ។

ប្រការ ១២ : ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិមានភារកិច្ចធ្វើទំនាក់ទំនងជាមួយប្រទេសណាដែល ត្រូវស្នើសុំ ការអនុញ្ញាតទ័ឆ្លងកាត់ ។

ប្រការ ១៣ : ក្រសួងស្ថាប័នដែលមានការទាក់ទងដល់ការអនុវត្តន៍សេចក្តីសំរេចនេះត្រូវយកចិត្តទុក ដាក់បំព្រួញលំដាប់លំដោយ នៃការធ្វើបែបបទរដ្ឋបាលឱ្យបានខ្លីបំផុត សំដៅជំរុញការអនុវត្តន៍ឱ្យមានប្រសិទ្ធភាពល្អ ។

ប្រការ ១៤ : ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់និងនេសាទ ក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវចេញសេចក្តីប្រកាសស្តីពីទំរង់បែបបទសុំនាំចេញឈើ តំរូកិច្ចសន្យាលក់នាំចេញ បរិមាណនិងគុណភាពនាំចេញ អត្រាពន្ធ និង កំរៃផ្សេងៗដែលត្រូវបង់ជូនរដ្ឋ និង កំណត់និយមន័យឈើកែច្នៃឱ្យបានច្បាស់លាស់ ។ ចំពោះតំលៃនាំចេញត្រូវកំណត់ទៅតាមថ្លៃទីផ្សារអន្តរជាតិដែលអន្តរក្រសួងកំណត់ ។

ប្រការ ១៥ : ក្នុងដំណាក់កាលដោះស្រាយបញ្ហាសេសសល់កន្លងមក ចំពោះអាជីវករដែលបានគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាលឱ្យនាំចេញរួចហើយ តែពុំទាន់បានអនុវត្តត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមទំរង់បែបបទនិតិវិធីថ្មីនេះ ។

ប្រការ ១៦ : ចំពោះសំណើថ្មីស្តីពីការសុំនាំចេញឈើមូល ឈើអារនិងឈើកែច្នៃ អាចប្រព្រឹត្តទៅបានលុះត្រាតែបានបញ្ចូលក្នុង កំរិតកំណត់ផែនការរដ្ឋ និង ក្រោយពីមានសេចក្តីប្រកាសអន្តរក្រសួងស្តីពីទំរង់បែបបទសុំនាំចេញឈើមូល ឈើអារ និង ឈើកែច្នៃ ដូចដែលបានកំណត់ក្នុងប្រការទី ១៤ នៃសេចក្តីសំរេចនេះ ។

ប្រការ ១៧ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់

និងនេសាទ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ត្រូវអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះ ហត្ថលេខានេះតទៅ ។

**ប្រការ ១៨ :** បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

# II- ការងារបណ្តាក្រសួង

## ១. ឯកសារក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

*រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៩៥*

### សារាចរលេខ ០០១ សរ.សហវ.គរ
### ស្តីពីការគ្រប់គ្រងមន្ត្រីរាជការគយ និង រដ្ឋាករ

យោងទៅតាមបទបញ្ញត្តិទាំងឡាយណាដែលមានចែងក្នុងច្បាប់ស្តីអំពីសហលក្ខន្តិកៈនៃមន្ត្រីរាជការស៊ីវិល អនុម័តដោយរដ្ឋសភា នាសម័យប្រជុំសាមញ្ញលើកទី ៣ និតិកាលទី ១ នៅថ្ងៃ សុក្រ ទី ២១ ខែ តុលា ឆ្នាំ ១៩៩៤ និង ផ្អែកទៅលើភាពចាំបាច់របស់ទីចាត់ការគយ-រដ្ឋាករ ក្នុងការគ្រប់គ្រងមន្ត្រីរាជការគយ-រដ្ឋាករឱ្យកាន់តែល្អប្រសើរ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសូមធ្វើការណែនាំស្តីពីការគ្រប់គ្រងមន្ត្រីរាជការគយ-រដ្ឋាករដូចខាងក្រោមនេះ ÷

## ១-ការតែងតាំងនិងការផ្លាស់ប្តូរមន្ត្រីរាជការគយ-រដ្ឋាករ

១-ការជ្រើសរើសមន្ត្រីរាជការគយ-រដ្ឋាករនឹងប្រព្រឹត្តទៅតាមការប្រឡងប្រជែង ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមិនទទួលយកនូវសំណើសុំផ្ទេរមន្ត្រីរាជការពីក្រសួង ស្ថាប័ននានាមកចូលបំរើក្នុងក្របខ័ណ្ឌមន្ត្រីរាជការគយ-រដ្ឋាករឡើយ

២-មន្ត្រីរាជការគយ-រដ្ឋាករដែលកំពុងបំរើការងារនៅទីចាត់ការគយ-រដ្ឋាករនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុនឹងត្រូវ ធ្វើការតែងតាំង និងផ្លាស់ប្តូរ ពីកន្លែងធ្វើការមួយទៅកន្លែងធ្វើការមួយទៀតទៅតាមសំណើរបស់លោកនាយកទីចាត់ការគយ -រដ្ឋាករឬទៅតាមការសំរេចដោយផ្ទាល់របស់ឯកឧត្តមទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

ការតែងតាំង និង ការផ្លាស់ប្តូរនឹងប្រព្រឹត្តទៅតាមករណីដូចតទៅ :

ក-ចំពោះមន្ត្រីរាជការគយ-រដ្ឋាករ ដែលទើបជ្រើសរើសបញ្ចូលថ្មីដោយសារការប្រឡងប្រជែងការតែងតាំងនិងការ ប្រគល់ភារកិច្ចទៅតាមកន្លែងធ្វើការនីមួយៗ ត្រូវផ្អែកលើ មូលដ្ឋានចំណាត់ថ្នាក់នៃការប្រឡង ។

ខ-ការផ្លាស់ប្តូរត្រូវធ្វើឡើងសំរាប់រយៈពេលពីរឆ្នាំម្តង ចំពោះភ្នាក់ងារគយ-រដ្ឋាករ និងបីឆ្នាំម្តងសំរាប់មន្ត្រីដឹកនាំ ចាប់ពីថ្នាក់ប្រធាន អនុប្រធានការិយាល័យ សាខា និងទីស្នាក់ការគយនិងរដ្ឋាករ ។ ក៏ប៉ុន្តែរយៈពេលស្នាក់នៅនេះអាចពន្យា ទៅដល់បួនឆ្នាំសំរាប់ភ្នាក់ងារគយ-រដ្ឋាករ និងប្រាំមួយឆ្នាំសំរាប់មន្ត្រីគយ-រដ្ឋាករ ក្នុងករណីដែលមន្ត្រីរាជការគយ-រដ្ឋាករនោះមានសមត្ថភាពជំនាញមានស្នាដៃល្អប្រសើរក្នុងការងារ មានភាពស្មោះត្រង់ក្នុងការបំពេញភារកិច្ចគោរពបានល្អនូវបទបញ្ជាផ្ទៃក្នុងរបស់អង្គភាពឬយោងទៅលើភាពចាំបាច់នៃសេចក្តីត្រូវការរបស់ទីកន្លែងធ្វើការនីមួយៗ ។ល។

ចំពោះមន្ត្រីរាជការគយ-រដ្ឋាករដែលបានទៅធ្វើការនៅតំបន់គ្រុនចាញ់រយៈពេលស្នាក់នៅនឹងត្រូវកាត់បន្ថយមកនៅត្រឹមមួយឆ្នាំសំរាប់មន្ត្រីរាជការគយ-រដ្ឋាករ ចាប់ពីថ្នាក់ប្រធានអនុប្រធានស្នាក់ការ សាខាគយ-រដ្ឋាករឡើងទៅ និងពីប្រាំ មួយខែទៅមួយឆ្នាំចំពោះ ភ្នាក់ងារគយ-រដ្ឋាករ ។ មន្ត្រីរាជការគយ-រដ្ឋាករ ក៏អាចបន្តការងារនៅកន្លែងដដែលបានប្រសិនមានការស្នើសុំ ។

មន្ត្រីរាជការគយ-រដ្ឋាករ នឹងត្រូវធ្វើការផ្លាស់ប្តូរទីកន្លែងធ្វើការ មុនរយៈពេលដូចបានកំណត់ខាងលើក្នុងករណី ដែលបានប្រព្រឹត្តអំពើខុសឆ្គងធ្ងន់ធ្ងរ ។

គ-ក្រោយពីការប្រគល់ភារកិច្ចជូនវិញបន្ទាប់ពីភាពនៅទំនេរដោយគ្មានប្រាក់បៀវត្ស ។

ឃ-យោងតាមតំរូវការចាំបាច់ និងផលប្រយោជន៍របស់អង្គភាព ( ឥរិយាបថរបស់មន្ត្រីរាជការគយ-រដ្ឋាករ ពុំអាចបន្តបំពេញភារកិច្ចនៅកន្លែងធ្វើការនោះតទៅទៀតបានដោយសារមានទំនាស់ ឬ បានប្រព្រឹត្តខុសឆ្គង ការរំសាយចោលការិយាល័យ សាខា និង ទីស្នាក់ការគយ-រដ្ឋាករ ការផ្ទេរអង្គភាពពីកន្លែងមួយទៅកន្លែងមួយទៀត.......)។

ការតែងតាំង និង ផ្លាស់ប្តូរអាចអនុវត្តបាន ក្រោយការចុះហត្ថលេខាលើប្រកាសរបស់ឯកឧត្តមទេសរដ្ឋមន្ត្រីនិងជា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

មន្ត្រីរាជការគយ-រដ្ឋាករណាដែលពុំបានទៅបំពេញភារកិច្ចតាមការតែងតាំង ឬ ការផ្លាស់ប្តូរក្នុងរយៈពេល ១៥ ថ្ងៃ ក្រោយពីការប្រគល់លិខិតបង្គាប់ការ នឹងត្រូវចាត់ទុកថាបានបោះបង់ចោលការងារ ។

## ២.ការឡើងឋានន្តរស័ក្តិ ឬឡើងថ្នាក់

ការឡើងឋានន្តរស័ក្តិ ឬឡើងថ្នាក់នៃមន្ត្រីរាជការគយ-រដ្ឋាករត្រូវធ្វើតាមវេនជ្រើសរើស ឬតាមវេនជ្រើសរើសនិង អតីតភាពជាមួយគ្នា ។ រយៈពេលអប្បបរមានៃការឡើងថ្នាក់ត្រូវកំរិត ២ ឆ្នាំ ។ ក្នុងករណីមន្ត្រីរាជការគយ-រដ្ឋាករណាម្នាក់ បំពេញការងារមានស្នាដៃល្អពិសេសត្រូវបានតម្លើងថ្នាក់ជាស្វ័យប្រវត្តិដោយពុំគិតលក្ខខ័ណ្ឌអតីតភាពឡើយ ។ ការតម្លើង ថ្នាក់ត្រូវមានការយល់ព្រមពីឯកឧត្តមទេសរដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទៅតាមកំរិតនៃកន្លែងទំនេរក្នុងឋានន្តរស័ក្តិនីមួយៗ ។

មន្ត្រីរាជការគយ-រដ្ឋាករ ក្នុងឋានន្តរស័ក្តិតែមួយអាចឡើងថ្នាក់ម្តងបានតែមួយថ្នាក់ បើផ្លាស់ឋានន្តរស័ក្តិត្រូវឡើងទៅថ្នាក់ក្រោមបំផុតនៃស័ក្តិខ្ពស់ជាងនោះ ។

## ៣.វិន័យ

មន្ត្រីរាជការគយ-រដ្ឋាករគ្រប់រូបត្រូវតែគោរពអនុវត្តច្បាប់ និង បទបញ្ជាហើយនិងការណែនាំពីថ្នាក់លើរបស់ខ្លួន ត្រូវទទួលខុសត្រូវចំពោះមុខថ្នាក់លើអំពីកិច្ចការរបស់ខ្លួន និងអំពើដែលអាចធ្វើអោយប៉ះពាល់ទៅលើសេចក្តីថ្លៃថ្នូរ និង កិត្តិយសរបស់ខ្លួន ត្រូវគោរពបញ្ជាថ្នាក់លើដែលបានចាត់ឱ្យទៅបំរើការងារទោះបីជាតំបន់ណាក៏ដោយ ។

មន្ត្រីរាជការគយ-រដ្ឋាករត្រូវបានហាមដាច់ខាត :

១-យកម៉ោងរដ្ឋបាលទៅប្រកបមុខរបរផ្ទាល់ខ្លួនផ្សេងៗទៀត ។

២-យកឥទ្ធិពលនិងអំណាចនៅក្នុងមុខងាររបស់ខ្លួនទៅប្រើ ដើម្បីទាញយកផលប្រយោជន៍អ្វីមួយ ឬដើម្បីសំឡុត គំរាមកំហែង បំពានសិទ្ធិពលរដ្ឋ ។

៣-ប្រកបមុខរបរណាដែលនាំឱ្យប៉ះពាល់ដល់កិត្តិយស និងសេចក្តីថ្លៃថ្នូរនៃមន្ត្រីរាជការគយ-រដ្ឋាករ ។

